**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ..០២..បប...

# បទបញ្ជា

## ស្តីពី

## ការទប់ស្កាត់ការនាំចូលសាច់ និង សត្វជ្រូករស់ពីបរទេស

ក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថាមានចលនានាំចូលសាច់ និង សត្វជ្រូករស់ពីបរទេសមកក្នុងប្រទេសកម្ពុជាតាមគ្រប់រូបភាព និង បែបអាណាធិបតេយ្យក្នុងខណៈដែលប្រទេសមួយចំនួនក្នុងតំបន់ បានផ្ទុះចេញនូវជម្ងឺឆ្លងជ្រូក ។ ចលនានៃការនាំចូលបែបអាណាធិបតេយ្យនេះបានក្លាយជាចលករនៃការផ្តល់លទ្ធភាពដល់ការឆ្លងរាលដាលជម្ងឺជ្រូកនៅកម្ពុជា និងជាការរាំងស្ទះ និងពន្យឺតល្បឿននៃការអភិវឌ្ឍន៍ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ដែលជាផ្នែកមួយសំខាន់ក្នុងការរួមចំណែកដល់ការធ្វើអោយសំរេចបាននូវគោលនយោបាយកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ ។ ពិនិត្យឃើញនូវស្ថានការណ៍មិនអំណោយផលនាពេលបច្ចុប្បន្ន ពិសេសដើម្បីទប់ស្កាត់ការនាំចូលសាច់ និង សត្វជ្រូករស់អោយមានប្រសិទ្ធភាព ក៏ដូចជាសំដៅធ្វើអោយសំរេចបាននូវកិច្ចអភិវឌ្ឍន៍ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារនៅកម្ពុជា រាជរដ្ឋាភិបាលចាំបាច់ដាក់ចេញនូវបទបញ្ជាដូចខាងក្រោម:

១. ក្រសួងមហាផ្ទៃត្រូវបញ្ជាដល់អាជ្ញាធរខេត្ត-ក្រុង ពិសេសខេត្ត-ក្រុង តាមបណ្តោយព្រំដែនអោយចាត់វិធានការបន្ទាន់ក្នុងការទប់ស្កាត់ការនាំចូលសាច់ និង សត្វជ្រូករស់មកក្នុងប្រទេសតាមគ្រប់រូបភាព និងគ្រប់ច្រកទាំងអស់ ។

២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវបញ្ជាដល់មន្ត្រីមានសមត្ថកិច្ចឈរជើងតាមព្រំដែនបញ្ឈប់ការអនុញ្ញាតអោយនាំចូលសាច់ និងសត្វជ្រូករស់មកក្នុងប្រទេសកម្ពុជា ។

៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវចាត់មន្ត្រីជំនាញ ដែលជាមន្ត្រីនគរបាលយុត្តិធម៌ចុះបង្ក្រាបការនាំចូលសាច់ និងសត្វជ្រូករស់នៅទូទាំងប្រទេស ពិសេសនៅតាមគ្រប់ច្រក នៃបណ្តាខេត្ត-ក្រុង តាមព្រំដែន ។

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវចាត់វិធានការចាប់ ឃាត់ទុក ឬ បំផ្លាញចោលសាច់ ឬ សត្វជ្រូករស់ទៅតាមវិធានបសុពេទ្យ និង នីតិវិធីជាធរមាន ។

៥. ក្រសួងស្ថាប័នពាក់ព័ន្ធ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការនគរបាលជាតិ និងអាជ្ញាធរដែនដី ពិសេសអាជ្ញាធរដែនដី នៃបណ្តាខេត្ត-ក្រុង តាមបណ្តោយព្រំដែន ត្រូវផ្តល់កិច្ចសហការដល់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អោយបំពេញការងារបានសំរេចតាមបទបញ្ជា ។

៦. ការនាំចូលកូនជ្រូកពូជសំរាប់បំពេញតំរូវការ នៃការចិញ្ចឹមក្នុងស្រុក និង សត្វជ្រូករស់សំរាប់បំរើការ ពិសោធន៍ស្រាវជ្រាវត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយចាំបាច់ ត្រូវត្រួតពិនិត្យអនាម័យ និង សុខភាពសត្វអោយបានត្រឹមត្រូវ ។

ទទួលបានបទបញ្ជានេះ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តអោយមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ ក្រសួង ស្ថាប័ន
- គ្រប់ សាលាខេត្ត-ក្រុង
- ឯកសារ កាលប្បវត្តិ